Empowered lives.
Resilient nations.

**PRESS RELEASE**

# ផ្តួចផ្តើមនវានុវត្តន៍ក្នុងវិស័យសាធារណៈ

**រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩៖** រាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) រៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ ដើម្បីពិភាក្សាអំពីលទ្ធភាពក្នុងការជម្រុញឱ្យមាននវានុវត្តន៍ក្នុងវិស័យអភិបាលកិច្ច ដែលជាកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យការផ្តល់សេវាដល់ប្រជាពលរដ្ឋកាន់តែល្អប្រសើរជាងមុន។

ក្រសួងមុខងារសាធារណៈ និង UNDP ប្រចាំប្រទេសកម្ពុជា បានសហការគ្នារៀបចំ **សិក្ខាសាលាថ្នាក់ជាតិស្តីពីវិស័យសាធារណៈក្នុងយុគសម័យឌីជីថល។** សិក្ខាសាលានេះ មានការចូលរួមពីអ្នកជំនាញមកពីក្នុងតំបន់ និងមន្ត្រីរាជការ ដើម្បីពិភាក្សាពីនវានុវត្តន៍ក្នុងវិស័យសាធារណៈ។

បដិវត្តន៍ឧស្សាហកម្មទីបួន ដែលនាំមកនូវការផ្លាស់ប្តូរក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក នាំឱ្យមានការរំពឹងចង់បាននូវសេវាសាធារណៈដែលកាន់តែមានភាពច្នៃប្រឌិតថ្មីជាងមុន និងផ្តល់ទាន់ពេលវេលាជាងមុន។ នវានុវត្តន៍ក្នុងវិស័យសាធារណៈ លែងជាអ្វីដែលធ្វើឱ្យវិស័យនេះមានភាពប្រណិតទៀតហើយ ប៉ុន្តែជាអ្វីដែលរដ្ឋាភិបាលក្នុងតំបន់ចាំបាច់ត្រូវតែធ្វើ ដើម្បីបន្តរៀបចំខ្លួន និងចូលរួមប្រកួតប្រជែងក្នុងសតវត្សរ៍ទី ២១។ កម្ពុជា គឺជាប្រទេសមួយ ក្នុងចំណោមប្រទេសជាច្រើន ដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងតំបន់ដែលត្រូវតែត្រៀមខ្លួនទប់ទល់ជាមួយនឹងការផ្លាស់ប្តូរនេះដើម្បីធានាថា តម្រូវការរបស់ប្រជាពលរដ្ឋត្រូវបាបំពេញប្រកបដោយប្រសិទ្ធិភាព។

ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបួន (២០១៩-២០២៣) រាជរដ្ឋាភិបាលកម្ពុជា បានគូសបញ្ជាក់យ៉ាងជាក់ច្បាស់ពីសារៈសំខាន់នៃគុណភាពធនធានមនុស្ស និងនវានុវត្តន៍បច្ចេកវិទ្យា និងបានចាត់ទុកជាចំណុចខ្លាំងគន្លឹះ ដើម្បីជួយឱ្យកម្ពុជា អាចច្បាមយកឱកាសប្រើប្រាស់ប្រព័ន្ធអេឡេត្រូនិច ក្នុងវិស័យអភិបាលកិច្ចរបស់ខ្លួនឱ្យបានកាន់តែច្រើន។ លើសពីនេះ ក្នុងកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវចក្ខុវិស័យច្បាស់លាស់ សម្រាប់ធ្វើកំណែទម្រង់រដ្ឋបាល ពោលគឺ «ធ្វើការផ្លាស់ប្តូររដ្ឋបាលសាធារណៈឱ្យក្លាយទៅជាអ្នកផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងជាដៃគូដែលអាចជឿទុកចិត្តបានដើម្បី ឈានទៅផ្តល់សេវាដល់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរជាងមុន»។

**ឯកឧត្តម កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ មានប្រសាសន៍ថា «កម្លាំងចលករទាំងនេះ គឺជាអ្វីដែលមានភាពចាំបាច់បំផុត ដើម្បីឱ្យកម្ពុជាអាចផ្តល់សេវាសាធារណៈ ដែលឆ្លើយតបទៅ

តាមការរំពឹងទុករបស់អ្នកប្រើប្រាស់ មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ កត្តាទាំងនេះ ក៏ជួយឱ្យកម្ពុជានៅតែបន្ត អាចចូលរួមប្រកួតប្រជែងក្នុងថ្នាក់តំបន់ និងក្នុងសកលលោក ក៏ដូចជាសម្រេចគោលដៅដើម្បីក្លាយជាប្រទេស មានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។»

សិក្ខាសាលានេះ ផ្តល់នូវវេទិកាឱ្យអ្នកចូលរួមស្វែងយល់ពីលទ្ធភាពយកបច្ចេកវិទ្យាឌីជីថល មកប្រើប្រាស់ក្នុងវិស័យសាធារណៈ ដើម្បីជួយឱ្យរាជរដ្ឋាភិបាលសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ពង្រឹងការជឿទុកចិត្តរបស់ប្រជាពលរដ្ឋលើប្រព័ន្ធអភិបាលកិច្ច និងផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព។

លោក Nick Beresford អ្នកតំណាង UNDP ប្រចាំប្រទេសកម្ពុជា បានគូសបញ្ជាក់ពីសារៈសំខាន់នៃនវានុវត្តន៍ថា «នៅពេលដែលគំនិតថ្មីៗមានប្រភពចេញពីមន្រ្តីរាជការខ្លួនឯង ភាគច្រើន គំនិតទាំងនេះនឹងនាំមកនូវការផ្លាស់ប្តូរពិតប្រាកដ។ ការងាររបស់យើង មិនមែននិយាយអំពីការអនុវត្តដែលល្អបំផុតនោះឡើយ ប៉ុន្តែគឺត្រូវជួយឱ្យក្រសួងនានាបើកចំហឱ្យមានឱកាសបញ្ចេញគំនិតច្នៃប្រឌិត ដើម្បីឱ្យមន្រ្តីរាជការអាចទៅកាន់តែកៀកនឹងប្រជាពលរដ្ឋ ដែលពួកគេផ្តល់សេវាឱ្យ និងយកដំណោះស្រាយដែលពួកគេគិតឃើញដោយខ្លួនឯងទៅធ្វើការពិសោធន៍សាកល្បង។»

## SPARKING INNOVATION IN THE PUBLIC SECTOR

**Phnom Penh, 04 March 2019** – The Royal Government of Cambodia and the UN Development Programme (UNDP) hold a National Conference looking at how to advance innovation in governance, in an effort to improve services to its people.

The Ministry of Civil Service and the UNDP in Cambodia have teamed up to launch the **National Conference on Public Sector in the Digital Era**. The Conference brings together experts and civil servants from across the region to discuss public sector innovation.

The Fourth Industrial Revolution that is transforming Asia and the Pacific is raising expectations for more innovative and timely public services. The need for public sector innovation is no longer a luxury but a must for governments to stay equipped and competitive in the 21st Century. The Royal Government of Cambodia is one of a number of emerging economies in the region preparing to deal with these changes to ensure that citizens' needs are satisfactorily met.

In the Fourth Rectangular Strategy (2019-2023), the Royal Government of Cambodia has clearly laid out the significance of improved human resource and technological innovation as key strengths for Cambodia to better deal with growing e-governance opportunities. Also in Cambodian National Program for Public Administration Reform, the Royal Government of Cambodia has clearly defined the vision for administrative reform as "to transform the public administration into an effective public service provider and a reliable partner towards serving people better".

"These drivers are indispensable for Cambodia to become more responsive, efficient and effective in delivering its public services. They also help Cambodia stay regionally and globally competitive,

and realize its goals of becoming a higher-middle income country and a developed country in 2030 and 2050 respectively," said **H.E. Ketebandith Pech Bunthin**, Minister of Civil Service.

The Conference provides a platform for participants to explore possibilities to adapt digital technologies within the public sector to support the Royal Government to achieve Cambodia's Sustainable Development Goals (CSDGs), strengthen citizens' trust in the governance system, and deliver public services more efficiently.

Speaking on the importance of innovation, **Nick Beresford**, UNDP Resident Representative, stressed that "when new ideas come from the civil servants themselves, they are much more likely to catch on and produce real change. Our job is not to dictate the best practice but to help ministries open up creative spaces so civil servants can get closer to the citizens they serve and test out their own solutions."

ENDS

***For media requests****, please contact* ***Mr. Samruol Im*** *at [samruol.im@undp.org](mailto:samruol.im@undp.org) or visit [https://bit.ly/2TkCi5e](https://bit.ly/2TkCi5e).*

***Follow us on social media:*** *Facebook Twitter LinkedIn Instagram*

***About UNDP***

*UNDP partners with people at all levels of society to help build nations that can withstand crisis, and drive and sustain the kind of growth that improves the quality of life for everyone. On the ground in nearly 170 countries and territories, we offer global perspective and local insight to help empower lives and build resilient nations. Learn more about UNDP here www.kh.undp.org.*